ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

រដ្ឋបាលព្រៃឈើ

FORESTRY ADMINISTRATION

# សេចក្តីប្រកាសព័ត៌មាន

រដ្ឋបាលព្រៃឈើបានកត់សម្គាល់ឃើញថា ក្នុងរយៈពេលប៉ុន្មានថ្ងៃនេះ នៅលើបណ្តាញសារព័ត៌មានក្នុងស្រុកមួយចំនួនបានផ្សព្វផ្សាយព័ត៌មានថា ការចរចារពិគ្រោះថ្លៃលក់វត្ថុតាងបទល្មើសផល អនុផលព្រៃឈើដែលបានបង្ក្រាបដោយគណៈកម្មការជាតិដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសធនធានធម្មជាតិ ស្ថិតក្នុងខេត្តមណ្ឌលគិរី ក្រចេះ និងត្បូងឃ្មុំ ហាក់បានឃុតឃិតគ្នាដេញថ្លៃតាមរបៀបចងមុងស្ងាត់ៗ និងការអនុញ្ញាតឱ្យបង្កើតរោងម៉ាស៊ីនអារកែច្នៃឈើនៅលើទីតាំងស្តុកឈើនៅកណ្តាលព្រៃ វាមិនខុសពីយកមេមាន់ទៅដាក់ឱ្យពងលើជង្រុកស្រូវនោះទេ ហើយដាក់ការសង្ស័យមកលើក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ករណីនេះ រដ្ឋបាលព្រៃឈើសូមធ្វើការបំភ្លឺដូចខាងក្រោម៖

១- ក្រុមហ៊ុន ធី.អេស.អិម.ជាប់ប៊ែលយូ ឯ.ក ដែលមានលោក សូ សាវ៉ាន ជាអភិបាលក្រុមហ៊ុន បានទទួលជ័យលាភីក្នុងការដេញថ្លៃលក់វត្ថុតាងបទល្មើសផល អនុផលព្រៃឈើដែលបានបង្ក្រាបមានបរិមាណឈើសរុប ៧ ៣៨៥ម³៩០៧ ដោយការអនុវត្តនីតិវិធីមានតម្លាភាព និងត្រឹមត្រូវដោយមានសមាសភាពចូលរួមពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គណៈកម្មការជាតិដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសធនធានធម្មជាតិ និងរដ្ឋបាលព្រៃឈើ ដោយបានដេញចាប់ពីតម្លៃមូលដ្ឋានស្មើនឹងទឹកប្រាក់សរុបចំនួន ៤ ០៥១ ២៩០ ០៩៦រៀល រហូតដល់ជ័យលាភីតម្លៃស្មើនឹងទឹកប្រាក់សរុបចំនួន ៥ ៦០០ ០០០ ០០០រៀល។

២- ការដឹកជញ្ជូនឈើមូលត្រូវបានហាមឃាត់ ហើយបញ្ហាភ្លើងព្រៃដែលប៉ះពាល់ឈើទាំងនោះ ដូច្នេះតម្រូវឲ្យក្រុមហ៊ុន ត្រូវបង្កើតរោងម៉ាស៊ីនអារកែច្នៃឈើចំនួន ៤កន្លែង ស្ថិតនៅទីនោះផ្ទាល់ ក្នុងខេត្តមណ្ឌលគិរី ដែលមានសុពលភាពរយៈពេលតែ ០៥ខែប៉ុណ្ណោះ។

៣- ការគ្រប់គ្រងចរាចរឈើ រដ្ឋបាលខេត្តមណ្ឌលគិរី បានចាត់សមាសភាពក្រុមការងារខេត្ត ដើម្បីចុះត្រួតពិនិត្យទីតាំងបង្កើតរោងម៉ាស៊ីនអារកែច្នៃឈើ និងផ្ទៀងផ្ទាត់បរិមាណឈើដេញថ្លៃដើម្បីលើកឡើងរថយន្ត តាមលិខិតបង្គាប់ការលេខ ០១៦/២០ លបក ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២០។

អាស្រ័យដូចបានជម្រាបជូនខាងលើនេះ សូមបណ្តាញសារព័ត៌មាន និងសាធារណជនមេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃសុក្រ ១០កើត ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២០

រដ្ឋបាលព្រៃឈើ

អាសយដ្ឋានលេខ ៤០ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារកណ្តាល២ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទ : (០២៣) ២១៤ ៦៥១ / ២១១ ៥៣៥ / ២១១ ៦៣៦
Nº 40, Preah Norodom Blvd, Sangkat Phsar Kandal 2, Khan Daun Penh, Cambodia Phone : (023) 214 651 / 211 535 / 211 636